រោគមហារីកដែលកម្រមាន

តើអ្នកដឹងទេ?

រោគមហារីករន្ធយោនី យោនី ហើយនឹងដៃស្បូនមិនសូវមានកើតជាញឹកញាប់ទេ។

តើអ្នកណានឹងអាចមានជំងឺនេះ?

អ្នកអាចមានជំងឺមហារីកទាំងនេះបើសិនជា៖

- អ្នកមានអាយុលើសពី៥០ឆ្នាំ។
- អ្នកធ្លាប់មានរោគមហារីកស្បូនឬក៏មហារីកទាក់ទងនឹងកន្លែងប្រដាប់បន្តពូជផ្សេងៗទៀត។
- អ្នកធ្លាប់មានកើតឫសដូងបាតដែលគេហៅថាអេជគីរី។

វិធីប្រសើរជាងគេដើម្បីការពារខ្លួនអ្នកគឺត្រូវរករោគមហារីកឲ្យឃើញមុន!

តើខ្ញុំត្រូវធ្វើដូចម្តេចដើម្បីការពារខ្លួនខ្ញុំ?

ទៅជួបវេជ្ជបណ្ឌិតឬក៏អ្នកព្យាបាលជំងឺដើម្បី៖

- ទទួលការពិនិត្យជាប៉ាបរាល់ឆ្នាំ (រួមជាមួយការពិនិត្យរន្ធយោនីនិងគូថជុះ)។
- ទទួលការពិនិត្យស្បូន(ផាប់គេស៍)។
- ពិភាក្សាអំពីរោគមហារីកដែលនឹងកើតមានឡើងនៅលើប្រមោយដៃស្បូនកស្បូននិងស្បូន។
- និយាយប្រាប់នូវលក្ខណៈនៃរោគសញ្ញាផ្សេងៗឬក៏អ្វីដែកអ្នកបានកតើសំគាល់។

រោគមហារីកប្រមោយដៃស្បូនគឺជាជំងឺពិបាកកត់សំគាល់ណាស់។ពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នកអំពីរោគសញ្ញាទោះបីវាមិនមានការទាក់ទង់ជាមួយនឹងប្រមោយដៃស្បូនក៏ដោយ។វេជ្ជបណ្ឌិតរបស់អ្នកអាចប្រើប្រដាប់ថតអូលត្រាសោននិងស៊ុមរ១២៥តាមការពិនិត្យឈាមដើម្បីជួយរកមហារីកប្រមោយដៃស្បូនបើសិនជាអ្នកនឹងមានជំងឺនេះ។

តើអ្វីទៀតដែលខ្ញុំត្រូវធ្វើដើម្បីឲ្យមានសុខភាពល្អ?

- ពិសារផ្លែឈើនិងបន្លែច្រាភាគក្នុងមួយថ្ងៃ។
- ធ្វើលំហាត់ប្រាណឲ្យបាន៣០នាទីក្នុងមួយថ្ងៃ។
- កំណត់ទម្ងន់ឲ្យនៅក្នុងលក្ខណៈដែលមានសុខភាពល្អ។
- ប្រើស្រោមអនាម័យនៅពេលរួមដំណេក។

ថ្ងៃខែសំខាន់ដែលត្រូវចាំ៖

ថ្ងៃមកពិនិត្យ៖
ថ្ងៃមកពិនិត្យជាបន្ទាប់៖

ឈ្មោះនិងលេខទូរស័ព្ទរបស់អ្នកព្យាបាលជំងឺ៖

សំរាប់ពត៌មានផ្សេងៗទៀតសូមទាក់ទង៖

The Cancer Information Service (se habla español)
1-800-4-CANCER, http://www.cancer.gov/cis

National Ovarian Cancer Coalition
1-888-OVARIAN, http://www.ovarian.org/

Women's Cancer Network
1-800-444-4441, http://www.wcn.org

ត្រូវការពត៌មាននេះ ឬក៏ជាអក្សរសំរាប់អ្នកខ្វាក់ ឬក៏ត្រូវការការសែតមើលឬក៏អក្សរធំ ឬក៏កុំព្យូទ័រ ឬក៏ទូរសព្ទហើយសរសេរទៅ Office of Women's Health, P.O. Box 997413 MS 0027, Sacramento, CA 95899-7413, phone (916) 440-7626, fax (916) 440-7636.

OWH OFFICE OF WOMEN'S HEALTH
CALIFORNIA DEPARTMENT OF HEALTH SERVICES

Arnold Schwarzenegger, Governor, State of California
S. Kimberly Belshé, Secretary, Health and Human Services Agency
Sandra Shewry, Director, California Department of Health Services

This pamphlet is also available on the OWH Web Site: www.dhs.ca.gov/director/owh.

Khmer–Gynecologic Cancers, Pub 306, 3/05

រោគមហារីករបស់ស្ត្រី ...

(មហារីករបស់ស្ត្រីដែលទាក់ទងនឹងកន្លែងប្រដាប់បន្តពូជ)

អ្វីទៅ ដែលស្ត្រី ត្រូវតែ ដឹង



អ្វីទៅជារោគមហារីកស្បូនរបស់ស្ត្រី

នេះគឺជារោគមហារីករបស់ស្ត្រីដែលកើតនៅកន្លែងប្រដាប់បន្តពូជ។
ជំងឺទាំងនេះគេហៅថារោគមហារីកស្បូនរបស់ស្ត្រី។
រោគទាំងនេះមាននៅលើ៖

- យោនី(បបេះនៅជុំវិញន្ទរយោនី)។
- ន្ទរយោនី(ទ្វារបង្កើតកូន)។
- កស្បូន(ទ្វារទៅស្បូន)។
- ស្បូន(ផ្ទៃសំរាប់កូន)។
- ដៃស្បូន(បំពង់បញ្ជូនពងទៅក្នុងស្បូន)។
- ប្រមោយដៃស្បូន(សំរាប់ពាំពងទុក)។

តើអ្នកណានឹងអាចមានជំងឺនេះ?

ស្ត្រីគ្រប់រូបអាចមានជម្ងឺនេះ។ អានកូនសៀវភៅនេះ
ហើយរៀនបន្ថែមទៀតអំពី៖

- ភាពដែលអាចកើតមានរោគនេះឡើង
- ជាតសញ្ញារបស់ជម្ងឺមហារីក
- របៀបរកឃើញជម្ងឺមហារីកឲ្យបានមុនពេលកំណត់

រោគមហារីកប្រមោយដៃស្បូន

តើអ្នកដឹងទេ?

ស្ត្រីភាគច្រើនបានស្លាប់ដោយសារជំងឺនេះច្រើនជាងជំងឺមហារីកដែលទាក់ទងនឹងកន្លែងប្រដាប់បន្តពូជ។

តើអ្នកណានឹងអាចមានជំងឺនេះ?

អ្នកអាចមានជំងឺមហារីកប្រមោយដៃស្បូនបើសិនជា៖

- អ្នកមានអាយុលើសពី៥០ឆ្នាំ។
- សមាជិកណាមួយនៅក្នុងគ្រួសាររបស់អ្នកធ្លាប់មានជំងឺមហារីកលើប្រមោយដៃស្បូនឬក៏លើដោះ។
- អ្នកមានមហារីកដោះ។
- អ្នកមិនធ្លាប់មានកូន។
- អ្នកធ្លាប់ពិសារថ្នាំហ័មនសំរាប់ស្ត្រីអស់រដូវ(ការប្រែប្រួលនៅក្នុងជីវិត)លើសពី១០ឆ្នាំកន្លងទៅ។

ភាគតិចដែលអ្នកអាចមានជំងឺមហារីកប្រមោយដៃស្បូនបើសិនជា៖

- អ្នកធ្លាប់ពិសារថ្នាំ(ភាលថ្នាំពន្យាកំណើត)លើសពី៥ឆ្នាំ។
- អ្នកធ្លាប់បំបៅដោះកូន។

អ្វីទៅដែលខ្ញុំត្រូវកត់សំគាល់?

ស្ត្រីជាច្រើនមិនមានរោគសញ្ញា។ជួនការវាពិបាកកំណត់សំគាល់សញ្ញាដែលទាក់ទងនឹងប្រមោយដៃស្បូន។ស្ត្រីខ្លះមាន៖

- ឈឺចុកចាប់មានអារម្មណ៍ពេញណែនឬក៏ដុះដុំនៅក្នុងពោះដែលមិនចេះស្រាកស្រាន្ត។
- ធ្លាក់ឈាមពីរន្ធយោនីដែលខុសប្លែកពីធម្មតា។
- មានបញ្ហាក្នុងក្រពះចង់ក្អួតឬក៏មិនស្រួលក្នុងពោះ។
- ឈឺចុកចាប់នៅពេលរួមដំណេក។

រោគមហារីកស្បូន

តើអ្នកដឹងទេ?

រោគមហារីកស្បូនជាជំងឺកើតឡើងជាញឹកញាប់ក្នុងចំណោមរោគមហារីកដែលទាក់ទងកន្លែងប្រដាប់បន្តពូជ។ រោគមហារីកនេះ
គេហៅថារោគលើស្បូនហើយជាទូទៅវាបង្កបង្កើតនៅលើស្រទាប់ក្នុងនៃផ្ទៃសំរាប់បង្កកូន។

តើអ្នកណានឹងអាចមានជំងឺនេះ?

អ្នកអាចមានជំងឺមហារីកស្បូនបើសិនជា៖

- អ្នកមានអាយុលើសពី៥០ឆ្នាំ។
- អ្នកមានជាតិខ្លាញ់ច្រើននៅក្នុងខ្លួនមានជំងឺទឹកនោមផ្អែមឬក៏មានជំងឺលើសឈាម។
- អ្នកពិសារថ្នាំហ័មនសំរាប់ស្ត្រីអស់រដូវ(ការប្រែប្រួលនៅក្នុងជីវិត)។
- អ្នកមិនធ្លាប់មានកូន។
- អ្នកអស់រដូវតាំងពីអាយុ៥២ឆ្នាំ។
- អ្នកពិសារថ្នាំតាម៉ុកស៊ីហ្វឹនដែលជាថ្នាំសំរាប់មហារីកដោះ។

អ្វីទៅដែលខ្ញុំត្រូវកត់សំគាល់?

ស្ត្រីជាច្រើនមិនមានរោគសញ្ញា។ជួនការវាពិបាកកំណត់សំគាល់សញ្ញាដែលទាក់ទងនឹងប្រមោយដៃស្បូន។ស្ត្រីខ្លះមាន៖

- ធ្លាក់ឈាមឬក៏ធ្លាក់សរពីរន្ធយោនីដែលខុសពីការធម្មតា។
- មានអារម្មណ៍ពេញណែនឬក៏ឈឺចុកចាប់នៅក្នុងពោះដែលមិនចេះស្រាកស្រាន្ត។
- ស្រកឬក៏ឡើងទម្ងន់ដោយមិនបាច់ខំប្រឹង។

រោគមហារីកកស្បូន

តើអ្នកដឹងទេ?

អ្នកអាចការពារកុំឲ្យកើតរោគមហារីកកស្បូនដោយសារការពិនិត្យស្បូន(ផាប់តេស៍)។ផាប់តេស៍អាចរកឃើញកោសិកាដែលមានលក្ខណៈខុសពីធម្មតាមុននឹងវាអាចក្លាយទៅជារោគមហារីក។

តើអ្នកណានឹងអាចមានជំងឺនេះ?

អ្នកអាចមានជំងឺមហារីកកស្បូនបើសិនជា៖

- មិនបានពិនិត្យស្បូន(ផាប់តេស៍)ឲ្យបានទៀងទាត់។
- អ្នកឬក៏គូរួមដំណេករបស់អ្នកធ្លាប់បានរួមដំណេកជាមួយដៃគូរច្រើនទៀត។
- អ្នកចាប់ផ្តើមរួមដំណេកតាំងពីនៅក្មេង។
- អ្នកធ្លាប់មានកើតឫសដូងបាត។
- អ្នកជក់បារី។

អ្វីទៅដែលខ្ញុំត្រូវកត់សំគាល់?

ស្ត្រីភាគច្រើនមិនមានរោគសញ្ញា។ស្ត្រីខ្លះមាន៖

- ធ្លាក់ឈាមធ្លាក់ឈាមតំណក់ៗឬក៏ធ្លាក់សរពីរន្ធយោនីដែលខុសពីធម្មតា។
- ធ្លាក់ឈាមបន្ទាប់ពីរួមដំណេក។
- ឈឺចិកចាប់នៅពេលរួមដំណេក។